# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំខែ មករា ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុង ខែមករា ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១.ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. <u>ការងាររដ្ឋបាល</u>

-ផ្ញើលិខិតលេខ ០០១/១០ លស.កកចយ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំណើសុំពន្យាអនុស្សារណៈនៃការយោគយល់គ្នារវាងវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម (EWMI ) និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរបស់វិទ្យាស្ថាន EWMI

-ផ្ញើលិខិតលេខ ០០២/១០ លស.កកចយ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១០ ជូនលោកស្រី សូហ្វី បារ៉ែន អនុប្រធានអង្គការអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពីសំណើសុំបន្តកិច្ចសហប្រតិបត្តិការគម្រោងគេហទំព័ររបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ

-ផ្ញើលិខិតលេខ ០០៣/១០ លស.កកចយ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សំណើសុំបញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិចំនួន ០៤ រូប ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលស្តីពីខ្មែរយូនីកូដ (UNICODE ) ដែលរៀបចំឡើងដោយ NIDA

-ទទួលលិខិតលេខ ៥២៣ លអជ.រប ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៣១ នៃទិវាជ័យជំនះ ៧មករា (០៧/០១/១៩៧៩- ០៧/០១/២០១០) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១០ វេលាម៉ោង០៨:០០ នាទី នៅទីធ្លាមុខសាលមហោស្រប ខេត្តតាកែវ

-ទទួលលិខិត២៣៩/០៩ គ.ប.ស.យ ចុះថ្ងៃទី៣១ធ្នូ ឆ្នាំ២០០៩ ពីខុមហ្វ្រែល (COMFREL)ស្តីពីស្នើដាក់ "លទ្ធផលលក្ខណសន្ទស្សន៍ នៃវិស័យអាទិភាពនៅ ២៤ មណ្ឌលខេត្ត-រាជធានី" ដែលកំណត់ដោយម្ចាស់ឆ្នោតក្នុងមណ្ឌលទាំង២៤ ទៅក្នុងសេចក្តីព្រាង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)២០០៩-២០១៣

-ទទួលលិខិតលេខ ០២ លអជ.រប ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ពីទីស្តីការគណៈរដមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម:

១-សេចក្តីព្រាងអនុសញ្ញាកុងស៊ុលកម្ពុជា-ចិន

២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនៃសាទ

៣-បញ្ហាផ្សេងៗ:សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ននីតិប្បញ្ញត្តិ "គម្រោងវិនិយោគអភិវឌ្ឍអនុស្ថានីយ៍ និងខ្សែបណ្តាញអគ្គីសនី២៣០គីឡូវ៉ុល ភ្នំពេញ-កំពង់ចាម ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទីនៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលសជណ ០១ សជណ.សសស ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការអំពាវដល់មន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រីទាំងអស់ដែលពុំទាន់បានចូលជាសមាជិកសមាជិកា សមាគមសង្គហសង្គមនៅឡើយ សូមរួសរាន់អញ្ជើញចូលរួមឱ្យបានគ្រប់គ្នា

-ទទួលលិខិតលេខ ០០៣/១០ កអក/គ.ជ.នា ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ស្តីពីកិច្ចប្រជុំដើម្បីពិភាក្សាការអនុវត្តន៍អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ២០៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបញ្ចប់ការអនុវត្តន៍កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ

-ទទួលលិខិតលេខ០០៤/០៩ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ស្តីពីកិច្ចប្រជុំស្តីពីការពិនិត្យលទ្ធផលនៃការអនុវត្តន៍ "ក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ របស់អង្គការសហប្រជាជាតិប្រចាំឆ្នាំ២០០៩ " និងការពិភាក្សានិងឯកភាពលើសេចក្តីព្រាង "ឯកសារក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិសម្រាប់ឆ្នាំ២០១១-២០១៥ " និងពិធីចុះហត្ថលេខាលើឯកសារក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ របស់អង្គការសហប្រជាជាតិ

-ទទួលលិខិតលេខ ០០២/១០ លឆត.អ.ប.អ.ព ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ ពីអង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីករណីផ្តល់យោបល់លើសំណើក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

-ទទួលលិខិតលេខ ១២ លអជ.រប ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ អញ្ជើញចូលរួមប្រជុំក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩-២០ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតពីអង្គការ "CCJAPIII" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការវាយតម្លៃលើការបំពេញមុខងារ របស់ក្រុមហ៊ុនទទួលការ "ឆ្នាំ២០០៩-១០" (Contractor Performance Assessment)

-ទទួលលិខិតពីអង្គការខុនរ៉ាត់អាដេណូអ័រ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពី " ការអភិវឌ្ឍន៍នៃវដ្តធម្មនុញ្ញ " ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ភ្នំពេញ

-ទទួលលិខិតលេខ ២១ លអជ.រប ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ស្តីពីការអញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីពិភាក្សាលើរបៀបវារៈមានៈ ១- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា ២-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា ៣- បញ្ហាផ្សេងៗ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ២០ លអជ.រប ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១០ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបការងារ វប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០០៩ និងលើកទិសដៅឆ្នាំ២០១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ វេលម៉ោង០៨:១៥ នាទី នៅសាលសន្និសីទចតុមុខ

-ទទួលលិខិត ពីធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១០ ស្តីពីការបញ្ជូនឈ្មោះមន្ត្រី មួយរូប ជាអ្នកសម្របសម្រួលក្រុមការងារបច្ចេកទេសចម្រុះជាមួយនឹងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ទទួលលិខិតលេខ២៣ លអជ.រប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ អញ្ជើញចូលរួមជាមួយ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឱ្យ ឯកឧត្តម Suya Prasad Subedi អ្នកសរសេររបាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាចូលជួបសម្តែងការគួរសម និងសវនាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ១០:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ០៤៤/១០ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ នូវរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំអន្តរក្រសួងស្តីពីការជម្រុញអនុវត្តអនុក្រឹត្យលេខ ២០៦ អនក្រ.បក ចុះថ្ងៃទី៣ ធ្នូ ឆ្នាំ២០០៩ ស្តីពីការបញ្ចប់ការអនុវត្តកម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែលលើលទ្ធផលការងារ

-ទទួលលិខិតលេខ ០៦៧/១០ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ស្តីពីការអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១៦របស់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម 16th Meeting of P&H TWTG

-ទទួលលិខិតលេខ ០៦២ ផក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ពីក្រសួងផែនការ ស្តីពីការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ដើម្បីពិភាក្សាលើសេចក្តីព្រាងទី២នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ (ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣)

-ទទួលសេចក្តីសម្រេចលេខ ០១០/១០/របវត.អគជ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ នូវសេចក្តីសម្រេចស្តីពីការបែងចែកជំនាញជាចៅក្រមតុលាការ និងចៅក្រមអយ្យការ សម្រាប់សិស្សចៅក្រមជំនាន់ទី៤ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

-ទទួលលិខិតលេខ ០៨៥/គ.ប/១០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការរៀបចំសិក្ខាសាលាអប់រំបន្តស្តីពី "ក្រមរដ្ឋប្បវេណី" ដែលធ្វើបទបង្ហាញដោយមេធាវីមកពីប្រទេសជប៉ុន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ១៥-១៨ ខែកុម្ភៈ ឆ្នាំ២០១០ នៅ (CJCC)

-ទទួលលិខិតលេខ ៣០ លអជ.រប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ចូលរួមក្នុងសវនាជាមួយ ឯកឧត្តម Jan Knutsson អគ្គនាយកក្រសួងការបរទេសស៊ុយអែត ទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម Lennart Linner ឯកអគ្គរដ្ឋទូតស៊ុយអែតប្រចាំនៅកម្ពុជា ក្រោមអធិបតីភាពរបស់ ឯកឧត្តម ច័ន្ទ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើប្រធានបទៈកំណែទម្រង់រដ្ឋបាល-ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ១០:៤៥ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ១០៥/១០ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្តីពីរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃសូចនាករតាមដានរួមគ្នា (JMIs)វឌ្ឍនភាពនៃការអនុវត្តសកម្មភាពអាទិភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ(RGC Aid Effectiveness Prrorities) និងសំណើសូចនាករតាមដានរួមគ្នាថ្មី សម្រាប់វេទិការកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ (3rd CDCF)

-ទទួលលិខិតលេខ ៣៤ លអជ.រប ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើៈ១-សេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ២-សេចក្តីព្រាងច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនិងឋានៈបុគ្គល ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ១៥:០០ នាទីនៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ១១រប.៩២១/១០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ពីសាលាដំបូងរាជធានីភ្នំពេញនូវរបាយការណ៍ប្រចាំឆ្នាំ២០០៩ ស្តីអំពីសកម្មភាពការងាររបស់សាលាដំបូង និអយ្យការអមសាលាដំបូងរាជធានី

## ខ. ការងារកំណែទម្រង់

-រៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ភ្នំពេញ

-ពិនិត្យសិក្សាសេចក្តីព្រាងសំណើក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

-ជួបជាមួយលោក(Lee Kiyoung)រដ្ឋអាជ្ញាក្រសួងយុត្តិធម៌កូរ៉េ ដើម្បីស្វែងយល់ពីការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតួនាទីរបស់ក្រសួងយុត្តិធម៌

**គ. ផ្សេងៗ**

-ចូលរួមប្រជុំអន្តរក្រសួង

-អញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ

១-សេចក្តីព្រាងអនុសញ្ញាកុងស៊ុលកម្ពុជា-ចិន

២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ

៣-បញ្ហាផ្សេងៗៈសំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ននីតិប្បញ្ញត្តិ "គម្រោងវិនិយោគអភិវឌ្ឍអនុស្ថានីយ៍ និងខ្សែបណ្តាញអគ្គិសនី២៣០គីឡូវ៉ុល ភ្នំពេញ-កំពង់ចាម ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទីនៅទីស្តីការគណៈរដ្ឋមន្ត្រី

- ស្តីពីការអញ្ជើញចូលរួមក្នុងអង្គ ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីពិភាក្សាលើរបៀបវារៈមានៈ ១- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីប្រព័ន្ធមតិកមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា ២-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា ៣-បញ្ហាផ្សេងៗ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

- អញ្ជើញចូលរួមជាមួយ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឱ្យ ឯកឧត្តម Suya Prasad Subedi អ្នកសរសេររបាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាចូលជួបសម្តែងការគួរសម និងសវនាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ១០:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ចូលរួមសន្និសីទអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការជាសាកល ដើម្បីជំរុញអភិបាលកិច្ចល្អនៅទីក្រុងណាហ្គូយ៉ា ប្រទេសជប៉ុនរយៈពេលបីថ្ងៃពីថ្ងៃទី២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០

**២_សន្និដ្ឋាន**

ក្នុងខែ មករា ឆ្នាំ២០១០ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាអង្គភាពប្រតិបត្តិបាន និងកំពុងរៀបចំឯកសារជាមូលដ្ឋានផ្សេងៗសម្រាប់ដំណើរការងារឆ្នាំថ្មី

**៣-ទិសដៅអនុវត្តក្នុងខែកុម្ភ**

-ប្រជុំពិនិត្យសេចក្ដីព្រាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ប្រជុំពិនិត្យសេចក្ដីព្រាងកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការបច្ចុប្បន្នកម្ម ២០១០-២០១៣

-ប្រជុំពិនិត្យសេចក្ដីព្រាងសំណើក្របខ័ណ្ឌបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

**៤-ទិសដៅអនុវត្តក្នុង ឆ្នាំ២០១០**

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្ដីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តសិក្សារៀបចំផែនការសកម្មភាពជំនួយផ្នែកច្បាប់

-បន្តអនុវត្តគម្រោងពង្រីកអង្គភាពនីតិកម្ម

-បន្តអនុវត្តគម្រោងបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

-បន្តអនុវត្តគម្រោងរៀបចំប្រព័ន្ធអំប៊ូស្មាន(Ombudsman)

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ gtz ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្ដីពីមុខងារស្ថាប័នរដ្ឋ

-បន្តគម្រោង UNDP ងស្ដីពីទិន្នន័យដៃគូអភិវឌ្ឍន៍ទាក់ទងនិងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

-បន្តពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាកសម្រាប់សិទ្ធិមនុស្ស"DIHR"លើកិច្ចសហប្រតិបត្តិការឆ្នាំ២០១០

*រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០*

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង**

**ស៊ុយ ម៉ុងលាង**